ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៨ ច.ស.៩៤

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី២៤-៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពី ការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដូចមានសេចក្តីទៅនេះ ÷

---

---

---

Collection by VCAT Professional Consultant

មាត្រា២០(ថ្មី).-

ក្រៅពីរោងចក្រ សហគ្រាស ដែលស្ថិតនៅក្រោមអំណាចច្បាប់ស្ដីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមានដូចតទៅ ៖

- ២០% ចំពោះប្រាក់ចំណេញដែលសំរេចបានដោយនីតិបុគ្គល
- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ដូចមានចែងខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គល

| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ១.០០០.០០០៛ | ១០% |
| ពី ១.០០០.០០១៛ ដល់ ១០.០០០.០០០៛ | ១៥% |
| ពី១០.០០០.០០១៛ ដល់ ២០.០០០.០០០៛ | ២០% |
| លើសពី ២០.០០០.០០០៛ | ៣០% |

មាត្រា ៥៥ (ថ្មី).-

ទោះក្នុងករណីណាក៏ដោយ ក្រុមរាជការ គ្រឹះស្ថាន ឬអង្គការសាធារណៈទាំងឡាយ ព្រមទាំងសហគ្រាសរដ្ឋ សហគ្រាសចម្រុះ សហគ្រាសដែលរដ្ឋឱ្យសម្បទាន ហើយនិងសហគ្រាសឯកជន ពុំអាចនឹងលាក់បំបាំងនូវការសម្ងាត់ ក្នុងវិជ្ជាជីវៈចំពោះភ្នាក់ងារពន្ធ ដែលបំពេញមុខងារជាផ្លូវការរបស់ខ្លួន ហើយមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ហើយដែលសាកសួរព័ត៌មាន និង ឯកសារផ្សេងៗដែលទាក់ទងនឹងពន្ធដារ និង ពន្ធអាករ ដើម្បីនឹងកំណត់ពន្ធអាករ ឬប្រមូលពន្ធអាករ ។

មាត្រា២.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ៣០ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់

ប្រមុខរដ្ឋស្ដីទី

ជា ស៊ីម

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២

ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទំនាក់ទំនងសភា

និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

និង ហិរញ្ញវត្ថុ

គាត ឈន់

Collection by VCAT Professional Consultant